**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៦៨/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៨

# ប្រកាសព័ត៌មាន ស្តីពី ការកែតម្រូវលើសារព័ត៌មាន ឌឹ ឃែមបូឌា ដេលី

នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ សារព័ត៌មាន **ឌឹ ឃែមបូឌា ដេលី** (The Cambodia Daily) បានធ្វើការចុះផ្សាយនូវព័ត៌មានទាក់ទងការបោះឆ្នោត ប្រាសចាកពីប្រតិទិន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ និង បទបញ្ជា និងនីតិវិធី របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ។

នៅលើទំព័រសារព័ត៌មានរបស់ខ្លួនជាភាសាខ្មែរ ទំព័រទី ៧ និងជាភាសាអង់គ្លេស ទំព័រទី ២៤ សារព័ត៌មាន **ឌឹ ឃែមបូឌា ដេលី** បានសរសេរថា ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប បានថ្លែងថា **ការធ្វើយុទ្ធនាការឃោសនានឹងចាប់ផ្តើមជាផ្លូវការនៅរវាងថ្ងៃទី ២៦ ខែឧសភា ដល់ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០៨** និងឃ្លាខុសមួយទៀតសរសេរថា **សម្ភារៈផ្សព្វផ្សាយត្រូវតែដកចេញអំឡុងរយៈពេល ១៥ថ្ងៃ មុនការបោះឆ្នោត** ។

នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំដដែលនេះ គ.ជ.ប បានធ្វើលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យធ្វើការកែតម្រូវឡើងវិញដោយត្រូវសរសេរថា **ការឃោសនាបោះឆ្នោតមានរយៈពេល ៣០ថ្ងៃ គឺចាប់ពីថ្ងៃទី ២៦ ខែមិថុនា ដល់ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០៨** ហើយ **គណបក្សនយោបាយត្រូវប្រមូលមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត** ។

ដូច្នេះ ការចុះផ្សាយខុសរបស់សារព័ត៌មាន **ឌឹ ឃែមបូឌា ដេលី** បានធ្វើឱ្យសាធារណៈជន ក៏ដូចជាគណបក្សនយោបាយទទួលព័ត៌មានមិនច្បាស់លាស់ អំពីដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ ។